# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធន ជូនចៅក្រមនិងព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីប្រាក់ឧបត្ថម្ភចៅក្រម

-បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី

-យោងតាមសំណូមពរចាំបាច់

### សម្រេច

**មាត្រា ១.-**

ចៅក្រម និងព្រះរាជអាជ្ញា ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវគណនាប្រាក់ឧបត្ថម្ភលើកដំបូង ដោយយកប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយគុណនឹង ០៨ខែ សម្រាប់និវត្តជន និងគុណ ០៧ខែ សម្រាប់ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដូចមានចែងក្នុងអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី។

**មាត្រា ២.-**

ការគណនាប្រាក់សោធនត្រូវគិតតាមប្រាក់បៀវត្សមូលដ្ឋានចុងក្រោយ នៃព្រះរាជក្រឹត្យ ដែលដាក់ចៅក្រម និងព្រះរាជអាជ្ញាឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ